**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ៣៣..៤០......PC.អក

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការផ្គត់ផ្គង់ឧបករណ៍រាវរកគន្លងខ្សែបណ្ដាញអគ្គិសនីក្រោមដីម៉ាក RIGID SeekTech SR-24 LE ថ្មី ចំនួន 01 Set និងឧបករណ៍បំពាក់បន្ថែម RIDGID SeekTech Locator 18V Adaptor ថ្មី ចំនួន 02 Sets សម្រាប់ជំនួសឧបករណ៍ចាស់ខូច ជូនអង្គភាពបណ្ដាញ នៃនាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា៖ អគ្គិសនីកម្ពុជានឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈ ស្ដីពី ការផ្គត់ផ្គង់ឧបករណ៍រាវរកគន្លងខ្សែបណ្ដាញអគ្គិសនីក្រោមដីម៉ាក RIGID SeekTech SR-24 LE ថ្មី ចំនួន 01 Set និងឧបករណ៍បំពាក់បន្ថែម RIDGID SeekTech Locator 18V Adaptor ថ្មី ចំនួន 02 Sets សម្រាប់ជំនួសឧបករណ៍ចាស់ខូច ជូនអង្គភាពបណ្ដាញ នៃនាយកដ្ឋានអាជីវកម្មចែកចាយ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋាន៖ អគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី 27 ខែ វិច្ឆិកា ឆ្នាំ 2024 តទៅរៀងរាល់ម៉ោងធ្វើការ ទូរស័ព្ទទំនាក់ទំនងលេខ៖ 092 65 23 57 និង Website: www.edc.com.kh ) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី 11 ខែ ធ្នូ ឆ្នាំ 2024 វេលាម៉ោង 11:00 នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើវេលាម៉ោង 15:10 នាទី ថ្ងៃទី 11 ខែ ធ្នូ ឆ្នាំ 2024 ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញ ឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

ថ្ងៃ.សុក្រ...៧.រោច....ខែ..កត្តិក....ឆ្នាំរោង ឆស័ក ព.ស២៥៦៨
រាជធានីភ្នំពេញ ថ្ងៃ.២២.....ខែ..វិច្ឆិកា...ឆ្នាំ២០២៤
**ស.ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហាន់_ទូច**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ


(Code: 24DQS024)